**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន អេស អ៊ី អ៊ី អេស គ្លូបល (ខេមបូឌា) ខូ អិលធីឌី
# និង
# តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ
# ក្រុមហ៊ុន អេស អ៊ី អ៊ី អេស គ្លូបល (ខេមបូឌា) ខូ អិលធីឌី

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ២ និង ៣០ នាទី នៅក្នុងរោងចក្រ **អេសអ៊ីអ៊ីអេស គ្លូបល(ខេមបូឌា) ខូ អិលធីឌី** មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះសម្ភារវត្ថុធាតុដើមសម្រាប់ផលិត ព្រមទាំងការលប់ចោលការបញ្ជាទិញពីអ្នកកម្មង់ទិញដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់កម្មករ និយោជិតចំនួន **៦៦**នាក់ រយៈពេលចំនួន**២ខែ គឺចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ២០២០** នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករ និយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវ ប្រាក់ឈ្នួលចំនួន **៣០ ដុល្លា** សម្រាប់កម្មករ និយោជិតម្នាក់ៗ ក្នុងមួយខែ។

អង្គប្រជុំបានចប់វេលាម៉ោង៣ និង ១៥នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

កណ្តាល ថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២០

**តំណាងកម្មករ និង តំណាងសហជីព**

ហំ ពុំ　　នី យុនអេង　　ភាន ថារ៉ូ

ស្រួល ផាន់ណា　　ហៀង យុអេង　　យ៉ាន់ នីន

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អេសអ៊ីអ៊ីអេស គ្លូបល (ខេមបូឌា) ខូ អិលធីឌី SEES GLOBAL (CAMBODIA) Co., Ltd. KINGDOM OF CAMBODIA

**MOON HYUNKEE**